ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

## ខ្លឹមសារស្តីពីជំនួបសម្តែងការគួរសម និងជម្រាបលារបស់ ឯកឧត្តម បូរកែវ ភូមិវង្សសៃ ឯកអគ្គរដ្ឋទូតនៃសាធារណរដ្ឋប្រជាធិបតេយ្យ ប្រជាមានិតឡាវ ប្រចាំកម្ពុជា ចំពោះ ឯកឧត្តម ប្រាក់ សុខុន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិនៃព្រះរាជាណាចក្រកម្ពុជា

នៅព្រឹកថ្ងៃទី២០ ខែមករា ឆ្នាំ២០២៦ នៅទីស្តីការក្រសួង **ឯកឧត្តម ប្រាក់ សុខុន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិ បានអនុញ្ញាតឱ្យ **ឯកឧត្តម បូរកែវ ភូមិវង្សសៃ** ឯកអគ្គរដ្ឋទូតវិសាមញ្ញ និងពេញសមត្ថភាពនៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ប្រចាំព្រះរាជាណាចក្រកម្ពុជា ចូលជួបសម្តែងការគួរសម និងជម្រាបលា ក្នុងឱកាសដែល **ឯកឧត្តមឯកអគ្គរដ្ឋទូត** បានបញ្ចប់បេសកកម្មការទូតនៅកម្ពុជាដោយជោគជ័យ។

**ឯកឧត្តម ប្រាក់ សុខុន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិ បានថ្លែងសរសើរដល់ ឯកឧត្តម បូរកែវ ភូមិវង្សសៃ ឯកអគ្គរដ្ឋទូតនៃសាធារណរដ្ឋប្រជាធិបតេយ្យ ប្រជាមានិតឡាវ ប្រចាំកម្ពុជា ដែលក្នុងអណត្តិរបស់**ឯកឧត្តមឯកអគ្គរដ្ឋទូត** ប្រទេសទាំងពីរបានផ្លាស់ប្តូរទស្សនកិច្ចថ្នាក់ដឹកនាំជាន់ខ្ពស់ទៅវិញទៅមកជាញឹកញាប់។

**ឯកឧត្តមឯកអគ្គរដ្ឋទូត** បានថ្លែងអំណរគុណ ព្រមទាំងមានកិត្តិយស និងមោទនភាពដែលបានមកបំពេញការងារការទូតនៅកម្ពុជារយៈពេល៤ឆ្នាំមកនេះ។ **ឯកឧត្តមឯកអគ្គរដ្ឋទូត**ក៏បានជម្រាបជូន**ឯកឧត្តមឧបនាយករដ្ឋមន្ត្រី**ពីភាពជោគជ័យនៃការរៀបចំមហាសន្និបាតលើកទី១២ នៃបក្សប្រជាជនបដិវត្តន៍ឡាវ កាលពីថ្ងៃទី៦-៨ ខែមករា ឆ្នាំ២០២៦ ដោយបានអនុម័តកម្មវិធីនយោបាយបក្ស និងផែនការសេដ្ឋកិច្ចរយៈពេល៥ឆ្នាំរបស់ស.ប.ប.ឡាវ។

ដោយឆ្នាំ២០២៦ នេះ ជាខួបលើកទី៧០ នៃការបង្កើតទំនាក់ទំនងការទូតរវាងប្រទេសទាំងពីរ និងដើម្បីអបអរខួបនេះ ប្រទេសទាំងពីរកំពុងរៀបចំដំណើរព្រះរាជទស្សនកិច្ចផ្លូវរដ្ឋរបស់**ព្រះបាទព្រះករុណានរោត្តម សីហមុនី** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជាទៅកាន់ប្រទេសឡាវ។

**ឯកឧត្តមឯកអគ្គរាជទូត** បានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជូនចំពោះ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ និងស្ថាប័នពាក់ព័ន្ធកម្ពុជានានា ដែលបានផ្តល់កិច្ចសហប្រតិបត្តិការ និងការគាំទ្រយ៉ាងជិតស្និទ្ធ ក្នុងអាណត្តិរបស់ឯកឧត្តម។

**ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** បានជូនពរ **ឯកឧត្តមឯកអគ្គរដ្ឋទូត**ជោគជ័យក្នុងការបំពេញភារកិច្ចថ្មី និងបានបញ្ជាក់នូវការត្រៀមខ្លួនរបស់កម្ពុជា ក្នុងការផ្តល់ការគាំទ្រ និងកិច្ចសហប្រតិបត្តិការជាមួយឯកអគ្គរដ្ឋទូតឡាវថ្មី ដើម្បីពង្រឹងចំណងមិត្តភាពទ្វេភាគីបន្ថែមទៀត៕

* * * * * *